# English for Study in Australia
# កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី

## LESSON 22– Exam time
## មេរៀនទី២២ ៖ ពេលប្រឡង

**STUDY NOTES**
**ឯកសារជំនួយមេរៀន**

**<u>តួអង្គ</u>**

Rocky:
រ៉ុកឃី៖ និស្សិតអន្តរជាតិ
Angel:
អែនជល៖ និស្សិតអន្តរជាតិ
John:
ចន ៖ និស្សិតបរទេសសិក្សានៅសាកលវិទ្យាល័យ
Marion:
មារៀន ៖ គ្រូបង្រៀន

**<u>សាច់រឿង</u>**

*រ៉ុកឃី មិនបានរៀនសូត្រឲ្យបានជិតដល់សម្រាប់ការប្រឡងឡើយ។ ហេតុនេះហើយ អែនជល និងចន ក៏បានផ្តល់ជាយោបល់ដល់គាត់។*

**<u>ព័ត៌មាន-របៀប និងវិធីសាស្ត្រសិក្សា</u>**

***ការមើល ៖*** *ប្រសិនបើលោកអ្នកប្រើប្រាស់របៀបសិក្សាដោយការមើល នោះលោកអ្នកនឹងក្តាប់បានព័ត៌មានបានយ៉ាងប្រសើរតាមរយៈរូបភាព ក្រាហ្វិក និងរូបសញ្ញា។ គន្លឹះក្នុងការសិក្សា៖ ចូរគូរបន្ទាត់ដោយប្រើប៊ិចពណ៌ផ្សេងៗគ្នា ដើម្បីជួយលោកអ្នកឱ្យចងចាំព័ត៌មាន។*

***ការស្តាប់ ៖*** *ប្រសិនបើលោកអ្នកមានរបៀបសិក្សាដោយការស្តាប់ នោះលោកអ្នករៀនសូត្របានយ៉ាងប្រសើរបំផុតតាមរយៈការបង្រៀន ការបង្ហាត់នៅក្នុងថ្នាក់ និងការពិភាក្សាជាមួយអ្នកដទៃ។ គន្លឹះក្នុងការសិក្សា ៖ មុនពេលធ្វើតេស្ត សូមពន្យល់អំពីប្រធានបទនោះទៅកាន់មនុស្សដទៃទៀត។ ការធ្វើបែបនេះ អាចជួយលោកអ្នកឱ្យយល់ច្បាស់ និងចងចាំចំណុចសំខាន់ៗ។*

***ការអាន/សរសេរ ៖*** *ប្រសិនបើលោកអ្នកប្រើរបៀបសិក្សាដោយការអាន/សរសេរ លោកអ្នកក្តាប់ព័ត៌មានបានល្អប្រសៀរពីការអានសៀវភៅ វចនានុក្រម សន្លឹកកិច្ចការឬជំនួយមេរៀន។ល។ គន្លឹះក្នុងការសិក្សា ៖ សរសេរគំនិត និងគោលការណ៍សាឡើងវិញ ដោយប្រើពាក្យពេចន៍ផ្សេងៗគ្នា ដើម្បីជួយលោកអ្នកឱ្យចងចាំ។*


© RadioAustralia/AMES 2008

***ចលនាវិញ្ញាណ ៖*** *ប្រសិនបើលោកអ្នកចូលចិត្តការសិក្សាដោយចលនាវិញ្ញាណ លោកអ្នកអាចសិក្សាបានយ៉ាងប្រសើរតាមរយៈការមើល ការភ្លក់រសជាតិ ការប៉ះពាល់ ការហិតក្លិន និងការស្តាប់។ លោកអ្នកអាចរៀនបានយ៉ាងប្រសើរតាមរយៈការធ្វើដំណើរសិក្សា និងការដកពិសោធន៍។ គន្លឹះក្នុងការសិក្សា ៖ ចុះទៅធ្វើទស្សនកិច្ចសិក្សានៅកន្លែងណាដែលពាក់ព័ន្ធនឹងផ្នែកនៃការសិក្សារបស់លោកអ្នក។*

***វិធីសាស្ត្រចម្រុះ៖*** *និស្សិតភាគច្រើន ទទួលបានព័ត៌មានតាមរយៈការរួមបញ្ចូលរបៀបនៃការសិក្សាទាំងអស់ខាងលើនេះ។ សូមស្វែងយល់របៀបសិក្សារបស់លោកអ្នកផ្ទាល់ តាមរយៈការបំពេញនៅកម្រងបញ្ជីសំណួរ VARK (មានការភ្ជាប់ទៅវិបសាយថ៍នេះនៅចុងឯកសារជំនួយមេរៀន)។*

© Copyright Version 7.0 (2006) held by Neil D. Fleming, Christchurch, New Zealand and Charles C. Bonwell, Green Mountain Falls, Colorado 80819 U.S.A.

**<u>ភាសា-សំនួនវោហារ និងឃ្លាប្រយោគដែលមានន័យមិនធម្មតា</u>**

| | |
|---|---|
| "Legend"<br>ខ្លាំងពូកែ ឬ អស្ចារ្យ | *ក្រៀមភាសារបស់យុវវ័យ និយាយនៅពេលនរណាម្នាក់ ឬខ្លួនឯងធ្វើអ្វីមួយគួរឱ្យកត់សម្គាល់។ ពាក្យនេះក៏អាចប្រើប្រាស់សម្រាប់ការចម្អកផងដែរ។* |
| "Get off my case!"<br>ចេញទៅ កុំរំខាន! | *ទុកឱ្យខ្ញុំធ្វើខ្លួនឯង។ ទុកឱ្យខ្ញុំនៅម្នាក់ឯង។* |
| A fighting chance<br>ឱកាសសមរម្យសម្រាប់ការសម្រេចជោគជ័យ | *ឱកាសសមល្មមក្នុងការធ្វើអ្វីមួយបានសម្រេចជោគជ័យ។* |
| To scare the life out of someone<br>ធ្វើឱ្យភ្ញាក់ផ្អើលឬភ័យសឹងបាត់ព្រលឹង | *ធ្វើឱ្យនរណាម្នាក់ភ័យតក់ស្លុត។* |
| "Just chill!"<br>ឈប់ទុក្ខព្រួយ | *ក្រៀមភាសារបស់យុវវ័យ។ សម្រួលអារម្មណ៍។ ឈប់ព្រួយ។* |

**<u>លំហាត់</u>**

**<u>១. វាក្យសព្ទសំខាន់ៗ</u>**

សូមផែកអត្ថន័យ និងការបញ្ចេញសំឡេងនៃពាក្យទាំងអស់នេះនៅក្នុងវចនានុក្រមរបស់លោកអ្នក ៖

| | | |
|---|---|---|
| (to) cram | (to) describe | (to) fail |
| increase | invigilator | pile |
| relief | results | sample |
| significant | (to) swot | twice |

## ២. ការហាត់រៀនភាសា លំហាត់គំរូ តេស្តស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស

ដើម្បីអាចចូលរៀនក្នុងវគ្គសិក្សាណាមួយនោះ លោកអ្នកត្រូវធ្វើតេស្តដើម្បីស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេសជាមុនសិន។ សូមកត់ចំណាំថា ការណែនាំក្នុងការធ្វើតេស្ត ជាទូទៅ សរសេរជាភាសាអង់គ្លេស (ដូចខាងក្រោម)។

Choose the word that best fits each space in the text below.
ចូរជ្រើសរើសពាក្យដែលសមស្របបំផុតសម្រាប់ដាក់ទៅក្នុងចន្លោះនៃអត្ថបទក្នុងប្រអប់ខាងក្រោម។

Cross one box for each number, eg: ☒
សូមគូសខ្វែងនៅក្នុងប្រអប់មួយសម្រាប់លេខនីមួយៗ។ ឧទាហរណ៍ ☒

**Examination rules**

The doors ______1______ the examination room will be opened 10 minutes before the starting time for the examination. You will not be allowed to ______2______the examination room more than half an hour after the starting time for the examination. ______3______will you be allowed to leave the examination room until half an hour after the starting time for the examination. ______4______ remember, you must hand your answers book ______5______ the invigilator before you leave the examination room.

| | | | | |
|---|---|---|---|---|
| 1. | ☐ of | ☐ at | ☐ through | ☐ open |
| 2 | ☐ go | ☐ enter | ☐ into | ☐ walk |
| 3. | ☐ not | ☐ or | ☐ nor | ☐ never |
| 4 | ☐ so | ☐ since | ☐ and | ☐ this |
| 5 | ☐ in | ☐ to | ☐ at | ☐ with |


© RadioAustralia/AMES 2008

## ៣. ឧបសគ្គក្នុងការប្រើប្រាស់ភាសា

*សូរសំឡេង ៖ ៤៖ សូមហាត់និយាយពាក្យដ៏លំបាក ដែលតម្រូវឲ្យមានការប្រឹងពត់អណ្ដាតរួចបញ្ចេញសំឡេងឲ្យបានឮៗ ៖*

**"Carl has a large glass of lager at half past three."**

## ៤. អាសយដ្ឋានអ៊ីនធើរណិតដែលមានប្រយោជន៍

| | |
|---|---|
| **ព័ត៌មាន ៖**<br>របៀបសិក្សាផ្ទាល់ខ្លួន | http://www.vark-learn.com/english/index.asp *( សូមជ្រើសរើសភាសា)*<br><br>ចិនកុកងឺ<br>http://www.vark-learn.com/mandarin/page.asp?p=questionnaire<br><br>ឥណ្ឌូណេស៊ី<br>http://www.vark-learn.com/Indonesian/page.asp?p=questionnaire<br><br>English:<br>http://www.vark-learn.com/English/page.asp?p=questionnaire |
| អំពីការធ្វើផែនទីគំនិត | http://en.wikipedia.org/wiki/Mind_Mapping |
| គន្លឹះក្នុងការសិក្សា | http://www.studytips.org/ |

ចម្លើយលំហាត់ទី 2: 1) of 2) enter 3) nor 4) and 5) to

ABC Radio Australia Radio Australia


© RadioAustralia/AMES 2008